# ជំងឺថ្លើមប្រភេទ B



American Liver Foundation
www.liverfoundation.org
**1-800-GO-LIVER**

Your Liver. Your Life.

## ហេតុអ្វីបានជាថ្លើមមានសារៈសំខាន់?

ថ្លើមគឺជាសរីរាង្គធំជាងគេលំដាប់ទីពីរក្នុងសារពាង្គកាយរបស់អ្នកដែលមានទីតាំងនៅខាងក្រោមឆ្អឹងជំនីផ្នែកខាងស្តាំ។ វាមានទម្ងន់ប្រមាណបីផោន មានរាងសំប៉ែតដូចជាបាល់ដែលធ្លាយខ្យល់អស់។

ថ្លើមមានតួនាទីជាច្រើនក្នុងសារពាង្គកាយពោលគឺវាបំលែងអាហារនិងទឹកដែលអ្នកបានបរិភោគអោយ ទៅជាថាមពល និងជីវជាតិដែលសារពាង្គកាយត្រូវការ ។

## អ្វីទៅជាជំងឺថ្លើមប្រភេទ B?

ជំងឺថ្លើមប្រភេទ B គឺជាប្រភេទជំងឺដែលបង្កឡើងដោយវីរុសថ្លើមប្រភេទ B (HBV) ។ វាធ្វើឲ្យថ្លើមឡើងហើម និងរាំងំដំណើរការជាប្រក្រតីរបស់ថ្លើម។ មានមនុស្សពេញវ័យប្រហែល 95% ដែលប្រឈមនឹងការឆ្លងវីរុសថ្លើម (លក្ខណៈស្រួចស្រាវ)ហើយអាចជាសះស្បើយទៅវិញក្នុងរយៈពេល6ខែ ដោយមិនបាច់ប្រើថ្នាំព្យាបាល ។

ជាមួយគ្នានេះដែរក៏មានមនុស្សពេញវ័យប្រមាណជា 5% ដែលផ្ទុកវីរុសថ្លើមពេញមួយជីវិតរបស់គេ (លក្ខណៈរ៉ាំរ៉ៃ) ប្រសិនបើពួកគេព្យាបាលមិនបានជោគជ័យ។ ទារកដែលកើតចេញពីម្តាយដែលមាន ផ្ទុករោគថ្លើមមានអត្រាវិវឌ្ឍទៅរកជំងឺថ្លើមដែលមានលក្ខណៈរ៉ាំរ៉ៃខ្ពស់។ វីរុសថ្លើមអាចបណ្តាលឲ្យ ក្លាយទៅជាជំងឺក្រិនថ្លើម មហារីកថ្លើម និងខ្សោយថ្លើម។

## តើមនុស្សប្រភេទណាដែលងាយឆ្លងជំងឺថ្លើមប្រភេទB នេះ?

អ្នកដែលប៉ះពាល់ផ្ទាល់ជាមួយនឹងអង្គធាតុរាវរបស់បុគ្គលដែលមានផ្ទុកមេរោគថ្លើម (មានដូចជា ឈាម ទឹកកាម ទឹករំអិលយោនី) ងាយនឹងឆ្លងបំផុត ។

- ទារកដែលកើតចេញពីម្តាយដែលមានមេរោគថ្លើម
- ធ្លាប់បានធ្វើការ ឬប៉ះពាល់ដោយផ្ទាល់ជាមួយនឹងអង្គធាតុរាវនៃសារពាង្គកាយ
- ធ្លាប់បានរស់នៅជាមួយអ្នកមានមេរោគថ្លើម
- ធ្លាប់បានរួមភេទជាមួយអ្នកមានមេរោគថ្លើម
- មានដៃគូរួមភេទច្រើន
- ធ្លាប់កើតជំងឺដែលឆ្លងតាមការរួមភេទ
- ជាបុគ្គលដែលរួមភេទជាមួយប្រុសដូចគ្នា
- ធ្លាប់បានចាក់ ឬសេពគ្រឿងញៀន (សូម្បីតែម្តង)
- ធ្លាប់បានធ្វើការ ឬស្នាក់នៅក្នុងគុក
- ធ្លាប់បានធ្វើដំណើរទៅកាន់ប្រទេសដែលជំងឺថ្លើមតែងតែរាតត្បាត
- ធ្លាប់បានលាងឈាម

## តើជំងឺថ្លើមប្រភេទB មានរោគសញ្ញាដូចម្តេច?

មនុស្សជាច្រើនដែលកើតជំងឺថ្លើមស្រួចស្រាវ ឬរ៉ាំរ៉ៃមិនមានលេចចេញជារោគសញ្ញាទេ។ ករណីដែលមានលេចចេញរោគសញ្ញារួមមាន អស់កម្លាំង ឡើងកំដៅ បាយមិនបាន ភើ ឈឺក្បាល ចុករួយ- សាច់ដុំ ឈឺចាប់នៅក្បែរថ្លើម ជំងឺខាន់លឿង (មានស្បែកលឿង និងភ្នែកឡើងស) ។

ជាទូទៅរោគសញ្ញាលេចចេញបន្ទាប់ពីឆ្លងបានពី 2 ទៅ 5 ខែ។ រោគសញ្ញាជាធម្មតាមានរយៈពេលជាច្រើនសប្តាហ៍ ហើយជួនកាលអាចអូសបន្លាយរហូតដល់ 6 ខែ។

## តើធ្វើរោគវិនិច្ឆ័យជំងឺថ្លើមប្រភេទ B ដូចម្តេច?

គេអាចធ្វើរោគវិនិច្ឆ័យជំងឺថ្លើមប្រភេទ B តាមរយៈការពិនិត្យឈាម។ ការពិនិត្យឈាមគឺធ្វើឡើងដើម្បីស្វែងរកថាតើសារពាង្គកាយមានអង់ទីគ័រឬ អត់។ អង់ទីគ័រគឺជាប្រូតេអ៊ីនដែលបង្កើតឡើងដោយប្រព័ន្ធភាពស៊ាំដើម្បីប្រឆាំងទៅនឹងវីរុស ។

## តើជំងឺថ្លើមប្រភេទ B អាចព្យាបាលតាមវិធីណា?

### លក្ខណៈស្រួចស្រាវ

ជាទូទៅវេជ្ជបណ្ឌិតតែងតែណែនាំឲ្យអ្នកជំងឺផឹកទឹកឲ្យបានច្រើន បរិភោគអាហារដែលមានជីវជាតិ និងចៀសវាងគ្រឿងស្រវឹង ។ អ្នកចាំបាច់ត្រូវទៅជួបគ្រូពេទ្យឲ្យបានទៀងទាត់ដើម្បីប្រាកដថាអ្នកបានជាសះស្បើយពីជំងឺ។

### លក្ខណៈរ៉ាំរ៉ៃ

មានជម្រើសព្យាបាលជាច្រើនសម្រាប់ជំងឺថ្លើមដែលមានលក្ខណៈរ៉ាំរ៉ៃដូចជា: tenofovir, adefovir dipivoxil, interferon alfa 2b, pegylated interferon alfa 2a, lamivudine, entecavir, and telbivudine។ ថ្នាំទាំងនេះអាចមិនមានប្រសិទ្ធភាពសម្រាប់អ្នកជំងឺថ្លើមប្រភេទ B ទាំងអស់ទេ។ អ្នកជំងឺដែលប្រើថ្នាំទាំងនេះត្រូវឲ្យវេជ្ជបណ្ឌិតត្រួតពិនិត្យមើលជាមុនសិនថាតើអាចមានផលរំខានដែលបណ្តាលមកពីឥទ្ធិពលថ្នាំឬទេ។

<u>អ្នកដែលមានផ្ទៃពោះមិនគួរប្រើថ្នាំព្យាបាលជំងឺថ្លើមទេ ប្រសិនបើមិនមានការណែនាំពីគ្រូពេទ្យ ។</u> ស្ត្រីដែលមានផ្ទៃពោះ ហើយមានជំងឺថ្លើមមួយចំនួនអាចទទួលការព្យាបាលដើម្បីការពារកុំឲ្យឆ្លងទៅទារក ។ ប្រសិនបើអ្នកមានផ្ទុកវីរុសថ្លើម អ្នកចាំបាច់ត្រូវទៅពិគ្រោះជំងឺជាមួយវេជ្ជបណ្ឌិតជំនាញ ពីជំរើសនៃការព្យាបាល និងត្រួតពិនិត្យមើលជំងឺមហារីកថ្លើមរៀងរាល់ 6-12 ខែម្តង។ ជាមួយគ្នានេះ អ្នកគួរតែពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិតអំពីវ៉ាក់សាំងការពារជំងឺថ្លើមប្រភេទ A ផងដែរ ។

## តើវិធីសាស្ត្រណាដែលមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ការរីករាលដាលជំងឺថ្លើមប្រភេទ B?

ការចាក់វ៉ាក់សាំងការពារឲ្យដល់អ្នកដែលមិនទាន់ផ្ទុកមេរោគថ្លើមគឺជាវិធានការល្អបំផុតក្នុងការទប់ស្កាត់ការឆ្លង។ វ៉ាក់សាំងការពារថ្លើមប្រភេទ B ជាទូទៅធ្វើឡើងចំនួនបីដង។ ពីរលើកដំបូងគឺធ្វើឡើងក្នុងរយៈពេល1ខែបន្តបន្ទាប់គ្នា ហើយលើកទីបីគឺធ្វើឡើងនៅក្នុងរយៈពេល 6 ខែបន្ទាប់។

**វិធីសាស្ត្រផ្សេងទៀតក្នុងការទប់ស្កាត់ការរីករាលដាលវីរុសថ្លើមប្រភេទB រួមមាន៖**

- ទៅជួបគ្រូពេទ្យដើម្បីពិនិត្យមើលថាតើអ្នកមានផ្ទៃពោះ ឬអ្នកចង់មានផ្ទៃពោះ
- មិនត្រូវប្រើម្ជុលរួមគ្នា
- អនុវត្តការរួមភេទដែលមានសុវត្ថិភាព
- មិនត្រូវប្រើឡាម ច្រាសដុសធ្មេញ ឬសម្ភារៈប្រើផ្ទាល់ខ្លួនផ្សេងទៀតរួមគ្នា
- មិនត្រូវបរិច្ចាកឈាម សរីរាង្គ ឬជាលិកាផ្សេងៗ
- សូមប្រើតែម្ជុល សម្ភារៈសម្រាប់សាក់ ឬឧបករណ៍ចាក់ទម្លុះស្បែកដែលស្អាតគ្មានមេរោគ
- ប្រាប់វេជ្ជបណ្ឌិត ទន្តបណ្ឌិត និងភ្នាក់ងារផ្តល់សេវាសុខភាពរបស់អ្នក

## តើអ្នកណាខ្លះគួរតែចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺថ្លើមប្រភេទ B ?

អ្នកដែលគួរតែចាក់វ៉ាក់សាំងប្រឆាំងនឹងវីរុសប្រភេទ B រួមមាន៖

- ទារកទើបនឹងកើត និងកូនក្មេង
- អ្នកដែលមានជំងឺថ្លើមដែលមិនមែនបង្កឡើងដោយវីរុសថ្លើមប្រភេទ B
- អ្នកដែលមានមេរោគអេដស៍
- បុគ្គលិកផ្តល់សេវាសុខភាព និង សេវាសង្គ្រោះបន្ទាន់ បុគ្គលិកយោធា អ្នកក្លូក និងអ្នកកប់សព
- អ្នកដែលបានលាងឈាម
- អ្នកដែលធ្វើការនិងស្នាក់នៅក្នុងគុក
- បុគ្គលិក និងអ្នកជំងឺដែលស្ថិតនៅស្ថាបនដែលងាយទទួលរងការឆ្លងជំងឺ
- អ្នកដែលមានដៃគូរួមភេទច្រើន
- បុរសរួមភេទជាមួយបុរស
- អ្នកដែលធ្លាប់បានចាក់ និងសេពថ្នាំញៀន
- អ្នកដែលដៃគូរួមភេទមានវីរុសថ្លើម ឬគ្រួសារដែលមានសមាជិកមានផ្ទុកវីរុសថ្លើម
- អ្នកដែលធ្វើដំណើរទៅប្រទេសដែលមានវីរុសថ្លើមជាធម្មតា
- ក្រុមជនជាតិភាគតិច ឬជាតិសាសន៍ដែលមានអត្រាឆ្លងខ្ពស់ដូចជា ជនជាតិអាស៊ី អ្នករស់នៅលើកោះប៉ាស៊ីហ្វិច ជនជាតិអាមេរិក ជនជាតិអាព្រិច-អាមេរិក អាមេរិកឡាទីន ជនជាតិដើមរបស់អាមេរិក និង ជនជាតិអាឡាស្កា។

## សេចក្តីសង្ខេប

- ជំងឺថ្លើមប្រភេទB គឺជាជំងឺថ្លើមដែលបង្កដោយវីរុសថ្លើមប្រភេទ B (HBV)
- វីរុសថ្លើមប្រភេទB រីករាលដាលតាមរយៈការប៉ះពាល់អង្គធាតុរាងសរីរាង្គដោយផ្ទាល់ ដូចជា ឈាម ទឹកកាម និង ទឹករំអិលយោនី
- មនុស្សពេញវ័យភាគច្រើន (95%) អាចទប់ទល់នឹងវីរុសថ្លើមបាន 6 ខែ។ មនុស្សដទៃដែលទទួលការឆ្លងរយៈពេលយូរ គេឲ្យឈ្មោះថាជាវីរុសថ្លើមប្រភេទ B លក្ខណៈរ៉ាំរ៉ៃ។
- ប្រហែល 5% នៃមនុស្សពេញវ័យឆ្លងអំឡុងពេលពេញវ័យវិវឌ្ឍទៅជាវីរុសថ្លើមប្រភេទ B លក្ខណៈរ៉ាំរ៉ៃ។ ចំណែកឯកូនក្មេងដែលឆ្លងជំងឺនៅពេលកើត 95%អាចវិវឌ្ឍទៅជាវីរុសថ្លើមប្រភេទ B លក្ខណៈរ៉ាំរ៉ៃ ។
- ជនជាតិអាមេរិក 1នាក់ ក្នុងចំណោម 20នាក់ឆ្លងវីរុសថ្លើមប្រភេទ B ។ ជនជាតិអាស៊ី និង ជនជាតិអាមេរិកដែលរស់នៅកោះប៉ាស៊ីហ្វិច 1នាក់ ក្នុងចំណោម 10នាក់មានផ្ទុកវីរុសថ្លើមប្រភេទ B ដែលមានលក្ខណៈរ៉ាំរ៉ៃ ។
- ការចាក់វ៉ាក់សាំងគឺជាវិធានការប្រសើរបំផុតក្នុងការការពារវីរុសថ្លើមប្រភេទ B។
- មនុស្សជាច្រើនដែលមានវីរុសថ្លើមប្រភេទ B មិនមានរោគសញ្ញា។
- វីរុសថ្លើមប្រភេទ B អាចធ្វើរោគវិនិច្ឆ័យតាមរយៈការធ្វើតេស្តឈាម។
- វីរុសថ្លើមប្រភេទ B លក្ខណៈរ៉ាំរ៉ៃអាចបណ្តាលទៅជាជំងឺក្រិនថ្លើមមហារីកថ្លើម និងខ្សោយថ្លើម។
- មានអ្នកជំងឺមួយចំនួន ការព្យាបាលអាចជួយប្រឆាំងនឹងវីរុសថ្លើមប្រភេទ B បាន ។

American Liver Foundation
www.liverfoundation.org

**1-800-GO-LIVER**

កូនសៀវភៅផ្សព្វផ្សាយនេះអាចបោះពុម្ពបានដោយសារជំនួយដ៏សប្បុរសពីក្រុមហ៊ុនចែកចាយឱសថ Bayer Healthcare និង ក្រុមហ៊ុនចែកចាយឱសថ Onyx

©2009 American Liver Foundation. All rights reserved.